AMBASSADE
DE FRANCE
AU CAMBODGE
Liberté
Égalité
Fraternité

INSTITUT FRANÇAIS
Cambodge

Liberté
Créativité
Diversité


ពន្លាបារាំង
កម្មវិធី

PAVILLON FRANCE
PROGRAMME

ថ្ងៃទី ១៣-១៧ ខែវិច្ឆិកា

13 – 17 novembre

20e SOMMET DE LA FRANCOPHONIE
PHNOM PENH 2026



ផែនទី | LÉGENDE

- **A** ភូមិហ្វ្រង់កូហ្វូនី
  Village de la Francophonie
- **A1** ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
  Village de la Francophonie (Espace Conférences)
- **A2** ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសម្តែងសិល្បៈវប្បធម៌)
  Village de la Francophonie (Scène Performances Culturelles)
- **B** វិទ្យាស្ថានបារាំងនៅកម្ពុជា (IFC)
  Institut français du Cambodge (IFC)
- **C** សាលសន្និសីទចតុមុខ
  Chaktomuk Conference Hall
- **D** The Last Stage Aquation

យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការ កែប្រែកម្មវិធី

Programme sous réserve de modifications.
Consultez le site de l'IFC pour rester informé.



Chers visiteurs, chers amis de la Francophonie,

La France est heureuse et fière de prendre part, à Phnom Penh, au 20ème Sommet de la Francophonie, où elle transmettra la présidence du Sommet au Cambodge pour les deux années à venir. Ce « passage de relai » entre nos deux pays représente une occasion privilégiée de célébrer la vitalité de l'amitié franco-cambodgienne et de réaffirmer notre attachement aux valeurs qui nous rassemblent : la langue française comme instrument de partage ; la diversité culturelle et linguistique comme richesse à préserver et nourrir ; l'éducation et l'attention portée aux jeunes générations ; la paix, la démocratie, le développement durable, autant de biens communs que nous devons plus que jamais chercher à préserver, pour leur avenir.

Au cœur du Village de la Francophonie, le Pavillon France met ainsi à l'honneur une coopération franco-cambodgienne vivante et ambitieuse. Pendant cinq jours, vous pourrez y découvrir la richesse de nos échanges, mais aussi les nombreuses opportunités de réussite professionnelle et de développement individuel qu'offre à la jeunesse un parcours francophone.

Nous vous souhaitons donc une belle visite du Pavillon France et espérons que les rencontres que vous y ferez vous donneront envie de faire vivre, à nos côtés, une Francophonie ouverte, créative et porteuse d'avenir.

Olivier Richard
Ambassadeur de France au Cambodge

ពន្លាបារាំង
PAVILLON FRANCE

ថ្ងៃទី ១៣-១៧ ខែវិច្ឆិកា
Du 13 au 17 novembre
de 10h à 20h

ចូលទស្សនាដោយឥតគិតថ្លៃ
Entrée libre

សមស្របសម្រាប់ទស្សនិកជនទាំងអស់
Tout public


ភូមិហ្វ្រង់កូហ្វូនី
VILLAGE DE LA FRANCOPHONIE

ពន្លាជាតិបារាំងសូមអញ្ជើញលោកអ្នកមកស្វែងយល់ពីភាពសម្បូរបែបនៃសកម្មភាពនានាដែលជាស្នូលនៃកិច្ច សហប្រតិបត្តិការរវាងប្រទេសបារាំង និងកម្ពុជា តាមរយៈប្រធានបទចំនួនបី៖ ភាសាបារាំង និងការចល័តទីសិក្សា វប្បធម៌ និងការបង្កើតស្នាដៃ ព្រមទាំងវិទ្យាសាស្ត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព។

នៅក្នុងពិព័រណ៍អន្តរកម្មនេះ ដែលបើកឲ្យទស្សនាជាបន្តបន្ទាប់ សូមលោកអ្នកមកស្វែងយល់ពីបុគ្គលនានាដែលបានចូលរួមជំរុញ និងពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ព្រមទាំងអាចចូលរួមសាកល្បងដោយផ្ទាល់ និងស្វែងយល់ពីធនធាននានា ដែលបានរៀបចំជូន។ តាមរយៈល្បែងកម្សាន្ត វីដេអូ អេក្រង់អន្តរកម្ម និងធនធានឌីជីថល កុមារ និងមនុស្សពេញវ័យ ទាំងអស់ត្រូវបានអញ្ជើញឲ្យស្វែងយល់ពីទិដ្ឋភាពដ៏សម្បូរបែបនៃសកម្មភាពកិច្ចសហប្រតិបត្តិរបស់យើង។

Le Pavillon France vous invite à découvrir la richesse des actions au cœur de la coopération entre la France et le Cambodge, à travers trois parcours thématiques : Langue française et mobilités, Culture et création, Sciences et développement durable.

Dans cette exposition interactive ouverte en continu, rencontrez celles et ceux qui font vivre ces liens, observez, manipulez et explorez les ressources proposées. Jeux, vidéos, écrans interactifs et ressources numériques invitent petits et grands à explorer les multiples facettes de notre action.



នៅចំណុចប្រសព្វរវាងនវានុវត្តន៍ និងការចងចាំពីវប្បធម៌ មានរ៉ឺកកង់បីមួយកំពុងរង់ចាំដឹកលោកអ្នកធ្វើដំណើរទៅកាន់យុគសម័យមាសនៃតន្ត្រីខ្មែរ។ សូមអញ្ជើញមកសន្ទនាជាមួយតួអង្គនិមិត្តរបស់អធិរាជសំឡេងមាស ស៊ិន ស៊ីសាមុត តាមរយៈបច្ចេកវិទ្យាបញ្ញាសប្បនិមិត្ត (AI) ដែលអភិវឌ្ឍដោយ Ask Mona។

À la croisée de l'innovation et de la mémoire culturelle, un *reumork* vous attend pour vous transporter au cœur de l'âge d'or de la musique cambodgienne : discutez avec Sinn Sisamouth, grâce à une intelligence artificielle développée par Ask Mona !

ការបណ្តុះទស្សនៈ៖ ជីវចម្រុះ និងកសិអេកូឡូស៊ីតាមរយៈរូបភាព

Cultiver les regards : Biodiversité et agroécologie en images

13.11.2026
11h

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)





©IRD/Yann Bigant

តើយើងអាចសម្លឹងមើលជីវចម្រុះក្នុងវិស័យកសិកម្មរបស់កម្ពុជាតាមទស្សនៈថ្មីបានយ៉ាងដូចម្តេច? ចាប់ពីមីក្រូសរីរាង្គក្នុងដី រហូតដល់ទេសភាពវាលស្រែ អ្នកថតរូប និងអ្នកស្រាវជ្រាវនឹងអញ្ជើញសាធារណជនឱ្យស្វែងយល់យ៉ាងស៊ីជម្រៅអំពីពិភពជីវិត ដើម្បីឱ្យយើងអាចយល់ឃើញលើសពីការលើកឡើងដែលបង្កឱ្យមានការព្រួយបារម្ភ។នៅពេលរូបភាពនីមួយៗ ត្រូវបានបង្ហាញនៅលើឆាក សាធារណជននឹងត្រូវបានអញ្ជើញឱ្យចូលរួមឆ្លើយ សំណួរ និងល្បែងសំណួរចំណេះដឹង ដើម្បីចូលរួមសង្កេត និងបញ្ចេញមតិ។

Et si l'on regardait autrement la biodiversité agricole du Cambodge ? Des micro-organismes du sol aux paysages de rizières, photographes et chercheurs invitent le public à une plongée dans le vivant pour dépasser les discours anxiogènes. À chaque image dévoilée sur scène, questions et quiz invitent le public à observer et réagir, avant qu'un intervenant ne présente en cinq minutes en quoi elle symbolise l'agriculture durable au Cambodge.

វិទ្យាសាស្ត្រ និងការអភិវឌ្ឍ ប្រកបដោយចីរភាព
Sciences et développement durable

រៀបចំ និងដឹកនាំដោយ | Organisé par

Institut de Recherche pour le Développement (IRD)
Centre de coopération internationale en recherche agronomique pour le développement (CIRAD)

"Scapin 26" ដកស្រង់ និងកែសម្រួលពីស្នាដៃល្ខោន "Les Fourberies de Scapin" របស់ Molière

Scapin 26
Adaptation des Fourberies de Scapin

13.11.2026
15h

ល្ខោន | THÉÂTRE

វិទ្យាស្ថានបារាំងនៅកម្ពុជា
INSTITUT FRANÇAIS DU CAMBODGE



©Jean-Sien Kin

គម្រោងបង្កើតស្នាដៃល្ខោនបែបចូលរួម នៃរឿង "Les Fourberies de Scapin" របស់ Molière បានប្រមូលផ្តុំយុវជនកម្ពុជាដែលចេះនិយាយភាសាបារាំង។ តាមរយៈដំណើរការសិក្សា និងអនុវត្ត ដែលរួមបញ្ចូលការរៀនភាសាបារាំង ការបញ្ចេញមតិដោយផ្ទាល់មាត់ ការសម្តែងល្ខោន និងការបង្កើតស្នាដៃរួមគ្នា អ្នកចូលរួមទាំងអស់ នឹងបង្កើតការសម្តែងល្ខោនមួយ ដែលអាចបញ្ចូលធាតុនៃវប្បធម៌ខ្មែរ ដើម្បីបង្កើតកិច្ចសន្ទនារវាងពិភពនៃការស្រមៃ និងការច្នៃប្រឌិតរបស់បារាំង និងកម្ពុជា។

Ce projet de création théâtrale participative des *Fourberies de Scapin* de Molière réunit de jeunes Cambodgiens francophones. À travers un parcours mêlant français, expression orale, jeu théâtral et création collective, le projet propose un dialogue entre les imaginaires français et cambodgiens, et intègre des références culturelles khmères à la pièce de Molière.

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

60 min

ដឹកនាំសម្តែង | Mise en scène

Eric Ellul & Charlotte Alesi-Hoffmann

តួសម្តែង| Interprètes

Sovanreaksa Seng ; Sovanchakriya Seng ; Odom Chhoeurn ; Kunthea Phoung ; Saony Khy ; Rachana Sophy ; Bunthy Loch ; Léo Sok ; Sreymao Sorl ; Sophakmorkat Sok ; Soben Bruyère-Oeur ; Ros Bruyère-Oeur ; Ratanak Muong

សញ្ញាសម្គាល់ភូមិសាស្ត្រ៖ បញ្ហាប្រឈម និងសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ដែនដី និងបេតិកភណ្ឌ

Les indications géographiques : Enjeux économiques, territoriaux et patrimoniaux

14.11.2026
10h

វេទិកាតុមូល | TABLE RONDE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



©Association suisse des AOP-IGP



© Philippe Garcia

សញ្ញាសម្គាល់ភូមិសាស្ត្រ (IG) ជួយលើកកម្ពស់ជីវភាព និងភាពរស់រវើកនៃតំបន់ជនបទក្នុងសហគមន៍ប្រើប្រាស់ភាសាបារាំង។ សញ្ញាទាំងនេះ ជួយពង្រឹងភាពធន់នៃសេដ្ឋកិច្ច ថែរក្សាចំណេះដឹង និងជំនាញប្រពៃណី ព្រមទាំងរួមចំណែកដល់សន្តិភាព ស្ថិរភាពសេដ្ឋកិច្ច និងអត្តសញ្ញាណដែនដី។ នៅចំពោះមុខវិបត្តិផ្សេងៗ និងការប្រែប្រួលអាកាសធាតុ សន្និសីទនេះ នឹងលើកយកមកពិភាក្សាអំពីដំណោះស្រាយនានាប្រកបដោយនវានុវត្តន៍ និងបច្ចេកវិទ្យាបៃតង ដែលជួយពង្រឹងភាពធន់នៃខ្សែសង្វាក់ផលិតកម្មក្នុងវិស័យពាក់ព័ន្ធ។ សន្និសីទនេះ ក៏នឹងគូសបញ្ជាក់ពីតួនាទីដ៏សំខាន់របស់សម្ព័ន្ធកម្មសិទ្ធិបញ្ញានៃសហគមន៍ប្រើប្រាស់ភាសាបារាំង ក្នុងការកសាងរៀបចំរចនាសម្ព័ន្ធ និងជំរុញកិច្ចសហប្រតិបត្តិការរវាងតួអង្គពាក់ព័ន្ធនានាក្នុងសហគមន៍ប្រើប្រាស់ភាសាបារាំង។

Les indications géographiques (IG) font vivre les territoires ruraux de l'espace francophone : elles renforcent la résilience économique, préservent les savoir-faire et contribuent à la paix, à la stabilité économique et à l'identité territoriale. Face aux crises et au changement climatique, cette conférence explorera les solutions innovantes et les technologies vertes qui contribuent à la résilience des filières. Elle soulignera le rôle structurant de l'Alliance francophone de la Propriété Intellectuelle et encouragera les coopérations entre acteurs de l'espace francophone.

វិទ្យាសាស្ត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
Sciences et développement durable

រៀបចំ និងដឹកនាំដោយ | Organisé par

Institut national de la propriété intellectuelle (INPI)
avec les acteurs de l'Alliance francophone de la propriété intellectuelle

ការសម្តែង | រឿងនិទានតាមរយៈក្បាច់រាំ "Des Livres et Moi !" (សៀវភៅ និងខ្ញុំ!)

Conte chorégraphique Des Livres et Moi !

14.11.2026
11h

ការសម្តែងផ្ទាល់ | SPECTACLE VIVANT

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសម្តែងសិល្បៈវប្បធម៌)
VILLAGE DE LA FRANCOPHONIE (SCÈNE PERFORMANCES CULTURELLES)



សូមអញ្ជើញមកស្វែងយល់ពីការបង្កើតស្នាដៃសិល្បៈជាភាសាបារាំងនៃតំបន់ប៉ាស៊ីហ្វិក! ក្រុមសម្តែង Troc en Jambes សូមនាំមកជូននូវរឿងនិទានតាមរយៈក្បាច់រាំមួយ ដែលសៀវភៅហាក់ដូចជាចេះរាំ រាងកាយចេះនិទានរឿង ហើយពាក្យពេចន៍ហាក់ដូចជាហោះហើរទៅលើអាកាស។ នេះជាការសាទរដល់សិល្បៈនៃចលនា ពិភពនៃការស្រមើស្រមៃ និងអារម្មណ៍នានាដែលសៀវភៅដាស់ឱ្យភ្ញាក់រលឹកឡើងនៅក្នុងខ្លួនយើង។

Venez découvrir la création artistique francophone du Pacifique ! La compagnie Troc en Jambes propose un conte chorégrapique où les livres dansent, où les corps racontent, et où les mots s'envolent. Une ode au mouvement, à l'imaginaire, et à ce que les livres réveillent en nous.

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

60 min
dès 3 ans

រៀបចំ និងដឹកនាំដោយ | Organisé par

Gouvernement de la Nouvelle-Calédonie
Centre de Rencontres et d'Echanges Internationaux du Pacifique (CREIPAC)

ជាមួយ | Avec

Mise en scène : Véronique Nave
Interprètes : Véronique Nave et Théo Besson
Décors : Lucile Bodin et Guillaume Boron
Costumes : Gabrielle Ambrym

កម្ពុជាគ្មានជំងឺឆ្កែឆ្កួត៖ ការបង្ការជំងឺដែលអាចសម្រេចបានតាមរយៈវ៉ាក់សាំង

Cambodge sans la rage : La prévention à portée de vaccin

14.11.2026
11h30

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



ជំងឺឆ្កែឆ្កួត នៅតែបណ្តាលឱ្យមានមនុស្សស្លាប់រាប់រយនាក់ជារៀងរាល់ឆ្នាំនៅកម្ពុជា ដោយសារកង្វះលទ្ធភាពទទួលបាន ឬការមិនទទួលយកការព្យាបាលបង្ការក្រោយពេលត្រូវសត្វខាំ។ ដើម្បីដោះស្រាយបញ្ហានេះ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានចាប់ផ្តើមគំនិតផ្តួចផ្តើម "VIRAGE" ដែលក្នុងនោះមានការប្រើប្រាស់ភាពយន្តខ្លី "កុំចាកចោលខ្ញុំ" (Ne me dis pas au revoir) របស់លោក Mathieu Lam ។ បន្ទាប់ពីការបញ្ចាំងខ្សែភាពយន្តខ្លីនេះ យើងក៏នឹងមានកិច្ចពិភាក្សាតុមូលមួយដែលប្រមូលផ្តុំអ្នកវិទ្យាសាស្ត្រ អ្នកផលិតភាពយន្ត និងអ្នកពាក់ព័ន្ធក្នុងវិស័យសុខភាពសាធារណៈ ដើម្បីស្វែងយល់ថា តើការនិទានរឿងតាមបែបវប្បធម៌ អាចក្លាយជាចលករជំរុញមួយដ៏មានប្រសិទ្ធភាពសម្រាប់ការចាត់វិធានការយ៉ាងដូចម្តេច។

La rage tue encore des centaines de personnes chaque année au Cambodge, faute d'accès ou de recours à la prophylaxie post-exposition. Pour y remédier, l'Institut Pasteur du Cambodge a lancé l'initiative « VIRAGE », qui s'appuie notamment sur le court métrage *Ne me dis pas au revoir* de Mathieu Lam. Après la projection du film, une table ronde réunissant scientifiques, cinéastes et acteurs de santé publique se propose d'explorer comment la narration culturelle peut devenir un levier d'action efficace.

រៀបចំ និងដឹកនាំដោយ | Organisé par

Institut Pasteur du Cambodge (IPC)

វិទ្យាសាស្ត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
Sciences et développement durable

វិធីសាស្ត្រ "សុខភាពតែមួយ" នៅកម្ពុជា

L'approche One Health au Cambodge

14.11.2026
14h

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE (ESPACE CONFÉRENCES)





វិធីសាស្ត្រ "សុខភាពតែមួយ" (One Health) ផ្តល់នូវទស្សនវិស័យរួមបញ្ចូលគ្នារវាងសុខភាពមនុស្ស សុខភាពសត្វ និងសុខភាពបរិស្ថាន។ នៅកម្ពុជា វិធីសាស្ត្រនេះ ត្រូវបានអនុវត្តដំបូងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងពីសត្វមកមនុស្ស (zoonoses) ដូចជាជំងឺឆ្កែឆ្កួត និងជំងឺផ្តាសាយបក្សី មុននឹងពង្រីកវិសាលភាពទៅដល់ភាពស៊ាំនឹងថ្នាំអង់ទីប៊ីយ៉ូទិក និងប្រព័ន្ធស្បៀងអាហារ។កិច្ចពិភាក្សាតុមូលនេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រឈមសំខាន់ៗទាំងនេះ ទាំងផ្នែកវិទ្យាសាស្ត្រ និងនយោបាយ ជូនដល់សាធារណជនទូទៅឱ្យបានទូលំទូលាយ ដើម្បីជំរុញការយល់ដឹង និងការចូលរួមគិតគូរ រួមគ្នាក្នុងសង្គម។

L'approche « Une seule santé » (One Health) propose une vision intégrée de la santé humaine, animale et environnementale, initialement appliquée au Cambodge pour lutter contre les zoonoses comme la rage et la grippe aviaire avant de s'étendre à l'antibiorésistance et aux systèmes alimentaires. Cette table ronde vise à démocratiser ces grands enjeux scientifiques et politiques auprès du grand public pour favoriser une prise de conscience collective.

វិទ្យាសាស្ត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
Sciences et développement durable

រៀបចំ និងដឹកនាំដោយ | Organisé par

Institut Pasteur du Cambodge (IPC) ; Institut de Recherche pour le Développement (IRD) ; Centre de coopération internationale en recherche agronomique pour le développement (CIRAD)

សម្របសម្រួលដោយ | Modéré par

Agence française de développement (AFD)

មិនមែន Aline ទេ... ប៉ុន្តែស្ទើរតែដូច! ខារ៉ាអូខេជាភាសាបារាំងជាមួយ Aline Afanoukoé

Ce n'est pas Aline... mais presque ! Karaoké francophone avec Aline Afanoukoé

14.11.2026
18h

ច្រៀងខារ៉ាអូខេ | KARAOKÉ

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសម្តែងសិល្បៈវប្បធម៌)
VILLAGE DE LA FRANCOPHONIE
(SCÈNE PERFORMANCES CULTURELLES)



© ARTE France

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

មិនមែន Aline ទេ... ប៉ុន្តែស្ទើរតែដូច! នៅល្ងាចថ្ងៃសៅរ៍នេះ សូមត្រៀមខ្លួនសម្រាប់ពេលវេលាដ៏អស្ចារ្យនៃការជួបជុំ និងការចែករំលែកក្រុមគ្នា តាមរយៈកម្មវិធីខារ៉ាអូខេទ្រង់ទ្រាយធំរបស់ Aline Afanoukoé! តើយើងអាចមិននឹកដល់បទ "Aline" របស់ Christophe បានយ៉ាងដូចម្តេច? វាជាបទចម្រៀងដ៏ល្បីល្បាញឆ្លងកាត់ជាច្រើនជំនាន់ ហើយទទួលបានប្រជាប្រិយភាពជាពិសេសនៅក្នុងប្រទេសកម្ពុជា។ នៅល្ងាចនេះ Aline មិនត្រឹមតែជាឈ្មោះចម្រៀងមួយប៉ុណ្ណោះទេ៖ Alineនឹងមានវត្តមាននៅលើឆាក ក្នុងចំណោមទស្សនិកជន តាមរយៈសម្លេងច្រៀង និងជាពិសេសនៅក្នុងវគ្គបន្ទរ (refrains) ដែលយើងទាំងអស់គ្នានឹងច្រៀងរួមគ្នា!

Ce n'est pas Aline... mais presque ! Samedi soir, place à un grand moment de partage : le karaoké géant d'Aline Afanoukoé ! Et comment ne pas penser à *Aline* de Christophe, titre culte de la chanson française qui a traversé les générations et qui connaît ici, au Cambodge, une popularité toute particulière ? Ce soir, Aline ne sera pas seulement un prénom : elle sera sur scène, dans le public, dans les voix et surtout dans les refrains que nous chanterons tous ensemble.

រៀបចំ និងដឹកនាំដោយ | Organisé par

Cité internationale de la langue française

ជាមួយ | Avec

Aline Afanoukoé

ព្រេងនិទានទាំងបី

Les Trois Contes : La Belle et la Bête, Peau d'Âne, Barbe Bleue

14.11.2026
19h

ល្ខោន | THÉÂTRE

THE LAST STAGE AQUATION



© Virekbot Reth Norodom

ការសម្តែងនេះ ចែកចេញជាបីឈុត ដោយមានការចូលរួមពីតួសម្តែងចំនួន ៩ រូបនៃក្រុមល្ខោន The Last Stage។ ស្មាដៃនេះ នាំមកជូនទស្សនិកជននូវរឿងនិទានល្បីៗចំនួនបីរបស់អក្សរសិល្ប៍បារាំង គឺរឿង "ព្រះនាង និងសត្វចម្លែក" (La Belle et la Bête) "ព្រះនាងស្បែកលា" (Peau d'Âne) និង "ពុកចង្កាខៀវ" (Barbe-Bleue) ដែលត្រូវបានកែសម្រួលជាភាសាខ្មែរ និងរៀបចំការសម្តែងតាមបែបសហសម័យ។

Ce spectacle en trois tableaux, réunit 9 acteurs de The Last Stage autour de trois contes majeurs de la littérature française : La Belle et la Bête, Peau d'Âne et Barbe-Bleue, adaptés en khmer dans une mise en scène contemporaine !

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

90 min

ជាមួយ | Avec

Cie The Last Stage

ដឹកនាំសម្តែង | Mise en scène

Karim Belkacem-Saadi

តួសម្តែង| Interprètes

Heng Dara, Hun Chilisar, Cheng Ratana, Nam Chanboth, Thong Sopheanith, Nou Sipheng, Chou Kuychay, Von Lyer & Tep Borey

កក់សំបុត្រ | Réservations

@THELASTSTAGEAAA

ភាសាបារាំង៖ ភាសាស្ពាន សម្រាប់លើកកម្ពស់ភាពចម្រុះនៃភាសា

Grand Débat : Habiter le plurilinguisme Le français, langue passerelle au service de la diversité linguistique

15.11.2026
10h

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



© Benjamin Gavaudo

ភាសាបារាំង និងការចល័ត
Langue française et mobilités

តើការរស់នៅ និងការបង្កើតស្នាដៃដោយប្រើប្រាស់ភាសាច្រើនមានន័យដូចម្តេច? បញ្ញវន្ត និងអ្នកពាក់ព័ន្ធក្នុងសហគមន៍ប្រើប្រាស់ភាសាបារាំង នឹងជួបជុំគ្នាដើម្បីស្វែងយល់អំពីតួនាទីរបស់ភាសាបារាំង ក្នុងនាមជាភាសាស្ពាន ដែលជួយលើកកម្ពស់ភាពចម្រុះនៃភាសា។ កិច្ចពិភាក្សា នឹងចាប់ផ្តើមជាមួយនឹងបទបង្ហាញប្រកបដោយអារម្មណ៍ជ្រាលជ្រៅរបស់អ្នកនិពន្ធបារាំងដើមកំណើតខ្មែរ គឺ លោក Jean-Baptiste Phou ដែលនឹងអានសម្រង់ខ្លីមួយចំនួនពីសៀវភៅរបស់លោកដែលមានចំណងជើងថា 80 mots du Cambodge (៨០ ពាក្យអំពីកម្ពុជា)។

Que signifie vivre et créer entre plusieurs langues ? Intellectuels et acteurs de la francophonie se retrouvent pour explorer le rôle du français comme langue passerelle au service de la diversité linguistique. Le débat s'ouvrira avec une intervention sensible de l'écrivain français d'origine cambodgienne Jean-Baptiste Phou, qui lira plusieurs extraits de son ouvrage *80 mots du Cambodge*.

ជាមួយ | Avec

Philippe Claudel, président de l'Académie Goncourt ; **Aline Afanoukoé**, journaliste & animatrice radio ; **Sothik Hok,** directeur de l'ONG SIPAR ; **Cynthia Eid,** présidente de la Fédération internationale des professeurs de français (FIPF) ; **Paul Rondin,** directeur de la Cité internationale de la langue française ; **Jeanne Pham Tran,** éditrice et écrivaine & **Jean-Baptiste Phou,** écrivain et artiste franco-cambodgien

រៀបចំ និងដឹកនាំដោយ | Organisé par

Cité internationale de la langue française

សំឡេងថ្មីៗនៃភាពយន្តកម្ពុជា

Les nouvelles voix du cinéma cambodgien

15.11.2026
16h30

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)





ខ្សែភាពយន្តខ្នាតខ្លីចំនួនប្រាំរឿង សំឡេងថ្មីៗរបស់យុវជនប្រាំរូប និងកម្មវិធីណែនាំដោយអ្នកជំនាញមួយ។ មកជួបជាមួយផលិតករភាពយន្តវ័យក្មេងកម្ពុជា ដែលបានចូលរួមក្នុងកម្មវិធី ចតុ រៀបចំឡើងក្នុងឆ្នាំ ២០២៥ ដោយស្ថានទូតបារាំងប្រចាំកម្ពុជា និងវិទ្យាស្ថានបារាំងនៅកម្ពុជា ហើយដែលក្រោយមកបានផលិតខ្សែភាពយន្តខ្នាតខ្លីចំនួនប្រាំរឿង ដោយមានការគាំទ្រពី ក្រុមផលិតកររបស់ Anti-Archive។ អ្នកដឹកនាំរឿង ផលិតករភាពយន្ត តួសម្តែង និងដៃគូពាក់ព័ន្ធនឹងខ្សែភាពយន្តទាំងនេះ នឹងមកជួបជុំគ្នាដើម្បីចែករំលែកបទពិសោធន៍ វិធីសាស្ត្រធ្វើការ និងចក្ខុវិស័យរបស់ពួកគេចំពោះវិស័យភាពយន្តឯករាជ្យនៅកម្ពុជា។

Cinq courts-métrages, cinq jeunes voix, un programme de mentorat. Venez à la rencontre des jeunes cinéastes cambodgiens qui ont fait partie du programme CHAKTO, porté en 2025 par l'ambassade de France au Cambodge et l'Institut français du Cambodge, et qui ont depuis réalisé 5 courts-métrages avec le soutien du collectif Anti-Archive. Réalisateurs, producteurs, acteurs et partenaires de ces films se retrouveront pour partager leurs expériences, leur manière de travailler et leur vision du cinéma indépendant cambodgien.

ជាមួយ | Avec

Davy Chou, réalisateur et co-fondateur d'Anti-Archive
Seng Savunthara & Phorn Sophanith, cinéastes et réalisateurs de CHAKTO Cinéma
Modératrice : **Linda Nguon** (Banh Mi Media)

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

ភាពយន្តខ្លី | Courts Métrages

Incident on the Mountain, Seng Savunthara
How to Cut a Watermelon, Soksan Roza
Rented Room, Phorn Sophanith
I Wish I Could Float, Thong Senghorng
So... My Darling Sou Monysak

CHAKTO

ការប្រគំតន្ត្រី បារាំង-កម្ពុជា

Concert France-Cambodge

15.11.2026
17h30

ការប្រគំតន្ត្រី | CONCERT

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសម្តែងសិល្បៈវប្បធម៌)
VILLAGE DE LA FRANCOPHONIE
(SCÈNE PERFORMANCES CULTURELLES)



© Maria Lucas

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

សូមអញ្ជើញមកទស្សនា និងស្តាប់ស្នាដៃតន្ត្រីបារាំង-ខ្មែរដ៏ពិសេសមួយ ដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់កិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី ដោយមានការចូលរួមពីសិល្បករបារាំង និងកម្ពុជា! ស្នាដៃនេះកើតចេញពីកម្មវិធីស្នាក់នៅដើម្បីបង្កើតស្នាដៃសិល្បៈរបស់លោកស្រី Anne Paceo នៅកម្ពុជា ក្នុងក្របខណ្ឌនៃកម្មវិធីចតុសំឡេង ២០២៥ (CHAKTO Son 2025) ។ ស្នាដៃតន្ត្រីនេះ នឹងរួមបញ្ចូលគ្នានូវចង្វាក់ចាប៍ហ្ស៍ (Jazz) តន្ត្រីប៉ុប (Pop) ចម្រៀងបារាំង តន្ត្រីអេឡិចត្រូនិក និងតន្ត្រីប្រពៃណីខ្មែរ តាមរយៈបទភ្លេងដើមដែលត្រូវបាននិពន្ធ និងរៀបចំឡើងជាពិសេសសម្រាប់ព្រឹត្តិការណ៍នេះ។

Venez découvrir une création musicale franco-khmère spécialement conçue pour le Sommet de la Francophonie, réunissant artistes français et cambodgiens ! Née de la résidence d'Anne Paceo au Cambodge dans le cadre du programme CHAKTO Son 2025, cette création mêlera jazz, pop, chanson française, électronique et musiques traditionnelles khmères, autour d'un répertoire original composé et arrangé spécialement pour l'événement.

ជាមួយ | Avec

Anne Paceo (batterie, chant, composition) ; **François Atlas** (guitare, chant, composition) ; **Lynn Nandar Htoo** (guitare basse et électronique) ; **Keo Dorivan** (flûtes) ; **Say Thola** (instruments à corde) ; **Sour Vanna** (percussions) & **Phorn Somalis** (chant)

សំឡេងថ្មីៗនៃសៀវភៅរឿងបែបឆាករូបភាពនៅកម្ពុជា

Les nouvelles voix de la bande dessinée cambodgienne

16.11.2026
10h

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



អ្នកគូររូប និងអ្នកនិពន្ធសាច់រឿងជំនាន់ថ្មីរបស់កម្ពុជាបានបង្ហាញខ្លួនហើយ! រួមជាមួយអ្នកបោះពុម្ពផ្សាយដែលបានគាំទ្រកម្មវិធីនេះ អ្នកនិពន្ធសាច់រឿង និងអ្នកគូររូបវ័យក្មេងនៃកម្មវិធីចតុសៀវភៅឆាករូបភាព (CHAKTO Livre) នឹងបង្ហាញជូនទស្សនិកជននូវដំណាក់កាលនានានៃការបង្កើតស្នាដៃរបស់ពួកគេ សៀវភៅរឿងបែបឆាករូបភាពដែលបានបង្កើតឡើងបន្ទាប់ពីបញ្ចប់កម្មវិធី ព្រមទាំងការគាំទ្ររបស់ប្រទេសបារាំងចំពោះវិស័យសៀវភៅនៅកម្ពុជា។ នេះជាឱកាសពិសេសមួយ ដើម្បីស្វែងយល់អំពីសៀវភៅរឿងបែបឆាករូបភាពថ្មីស្រឡាងចំនួនប្រាំចំណងជើងជាភាសាខ្មែរ និងស្វែងយល់ពីភាពសម្បូរបែបនៃពិភពស្រមៃ និងការច្នៃប្រឌិតរបស់កម្ពុជា។

La nouvelle génération d'illustrateurs et scénaristes cambodgiens se dévoile ! Aux côtés des éditeurs qui ont encadré le programme, les jeunes scénaristes et illustrateurs de CHAKTO Livre vous dévoilent les étapes de création de leurs œuvres, les bande-dessinées créées à l'issue du programme, et le soutien de la France à la filière livre au Cambodge. Une occasion unique de découvrir cinq bandes dessinées inédites en khmer, et la richesse des imaginaires cambodgiens.

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création



ជាមួយ | Avec

Socheata Huot, éditions Avatar
Sovanrattana Sin, éditions Sipar
Hay Chhouem, Parkinha Leng, Pheanouk Tan, Socheat Chea, Piseth Keo, Solida Ouch, Chanreaksmey Som, Ly Seng, Khatriya Leng & Uddam Pen, les auteurs et illustrateurs de CHAKTO Livre
Modératice : **Linda Nguon** (Banh Mi Media)

CHAKTO

“កុំមាត់” សៀវភៅ ម៉ង់ហ្គ្រា (Manfra) ជាភាសាខ្មែរ៖ ជួបជាមួយលោក Yoann Vornière

Silence, un manfra à voix khmère : Rencontre avec Yoann Vornière

16.11.2026
11h15

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



© Aude Boyer

សូមអញ្ជើញមកជួបផ្ទាល់ជាមួយលោក Yoann Vornière ដែលជាអ្នកនិពន្ធសៀវភៅម៉ង់ហ្គ្រាដំបូងគេ (Manfra - ម៉ង់ហ្គាបារាំង) ដែលមានស្នាដៃត្រូវបានបកប្រែជាភាសាខ្មែរ ដោយគ្រឹះស្ថានបោះពុម្ពផ្សាយស៊ីប៉ា! លោកនឹងចែករំលែកអំពីដំណើរការងាររបស់លោក ការបង្កើតស្នាដៃ "កុំមាត់"និងការធ្វើដំណើរការនៃការនាំយកស្នាដៃនេះមកកាន់ប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នេះ ក៏នឹងផ្តល់នូវជ្រុងមួយនៃទិដ្ឋភាពផ្នែកក្នុងនៃវិស័យសៀវភៅនៅកម្ពុជា ព្រមទាំងតួនាទីរបស់ប្រទេសបារាំងក្នុងការគាំទ្រដល់ការបកប្រែស្នាដៃបារាំងជាច្រើនមកជាភាសាក្នុងស្រុក តាមរយៈកម្មវិធីជំនួយដល់ការបោះពុម្ពផ្សាយ (PAP - Plan d’aide à la Publication)។

Venez à la renconre de Yoann Vornière, premier auteur de manfra à voir son oeuvre traduite en khmer par les éditions Sipar ! Il abordera son parcours, la création de *Silence* et le voyage de l’oeuvre au Cambodge. Un aperçu des dessous de la filière du livre au Cambodge et du rôle de la France dans le soutien à la traduction de nombreuses oeuvres françaises en langues locales à travers le PAP - Plan d’aide à la Publication.

ជាមួយ | Avec

Yoanna Vornière, auteur du manga *Silence*
Sodany Ouch, édition Sipar, traductrice en khmer du manga
Gabriel Tatibouet-Sadki, Association pour la promotion de la traduction littéraire
Modératice : **Linda Nguon** (Banh Mi Media)

វប្បធម៌ និង
ការច្នៃប្រឌិត
Culture
et Création



Choix Goncourt du Cambodge 2026

16.11.2026
16h

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE (ESPACE CONFÉRENCES)

DÉBAT ET REMISE DE PRIX



© DR

Le Choix Goncourt du Cambodge s'inscrit dans le réseau international des Choix Goncourt, sous l'égide de l'Académie Goncourt. Tout au long de l'année, des étudiants et lycéens cambodgiens lisent et débattent autour de la sélection du Prix Goncourt avant de désigner leur propre lauréat. La séquence au Village de la Francophonie constitue l'aboutissement de ce parcours et met en lumière leur engagement ainsi que la richesse de la littérature contemporaine en français. Un grand débat réunissant étudiants, représentants d'université, spécialistes de la littérature aura lieu dans un premier temps pour revenir ensemble sur la sélection des livres Goncourt, avant la remise tant attendue du premier Choix Goncourt du Cambodge, en présence de Philippe Claudel, président de l'Académie Goncourt !

Avec

Philippe Claudel, président de l'Académie Goncourt
Représentants des universités participantes, du lycée français René Descartes & étudiants et lycéens membres du jury.
Modératrice : **Laetitia Dion,** agrégée et docteure de lettres modernes

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

Livres Goncourt

La Nuit au cœur, Nathacha Appanah
Kolkhoze, Emmanuel Carrère
Le bel obscur, Caroline Lamarche
La Maison vide, Laurent Mauvignier

NÄSS (មនុស្សលោក)
NÄSS (Les Gens)

16.11.2026
19h

របាំ | DANSE

សាលសន្និសីទចតុមុខ
CHAKTOMUK



© Gwendal Le Flem

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

60 min

អ្នកបង្កើតក្បាច់រាំរូបនេះ រំឭកដល់ឥទ្ធិពលដ៏វិសេសវិសាលរបស់ក្រុមតន្ត្រី Nass el Ghiwane នៅប្រទេសម៉ារ៉ុក នាទសវត្សរ៍ឆ្នាំ ១៩៧០។ ដោយយកតន្ត្រីប្រពៃណីជាប្រភពបំផុសគំនិត ក្រុមនេះក៏មានសំឡេងស៊ីចង្វាក់គ្នាជាមួយនឹងចលនាតវ៉ារបស់មហាជនផងដែរ។ តើចំណុចនេះមិនមានភាពស្រដៀងគ្នានឹងតួនាទីដែលតន្ត្រីហ៊ីបហប (Hip-Hop) មានកាលពីដើមដំបូងទេឬ? នៅលើឆាក អ្នករាំបុរស ៧ រូប នឹងបង្ហាញពីសមត្ថភាពដ៏ស្ទាត់ជំនាញនៃបច្ចេកទេសរាំយ៉ាងសម្បូរបែប ដោយម្នាក់ៗបង្ហាញពីភាពលេចធ្លោ និងអត្តសញ្ញាណផ្ទាល់ខ្លួនយ៉ាងមុតមាំ។ ស្នាដៃនេះ ជាផ្នែកមួយនៃការបន្តរបស់កម្មវិធីចតុរបាំ (CHAKTO Danse) ដែលលោក Fouad Boussouf ធ្លាប់ជាគ្រូបង្ហាត់ក្នុងឆ្នាំ ២០២៥។ ការសម្តែងនៅភ្នំពេញ នឹងបើកឆាកសម្រាប់ទស្សនកិច្ចសម្តែងក្នុងតំបន់ នៅខេត្តសៀមរាប និងបន្តទៅទីក្រុងហាណូយ។

Dans *Näss (Les Gens)*, le chorégraphe Fouad Boussouf orchestre une rencontre à haute intensité entre sept hommes, mêlant rythmes traditionnels nord-africains et mouvements urbains. S'inspirant des légendaires pionniers marocains de la musique gnawa, Nass el Ghiwane, Fouad Boussouf trouve une puissante analogie avec la quête d'identité et de racines propre au hip-hop. La pièce s'inscrit dans la continuité du programme CHAKTO Danse, dont Fouad Boussouf a été mentor en 2025. La représentation à Phnom Penh ouvrira une tournée régionale à Siem Reap, puis à Hanoï.

រៀបចំ និងនាំមកជូនដោយ | Présenté par

Chorégraphe : Fouad Boussouf
Interprètes : Adam Chado, Matthieu Convert, Morgan Gruvel, José Meireles, Akciel Régent Gonzalez, Derhen Têtu, Elie Tremblay

អ្នកស្ម័គ្រចិត្តរួបរួមគ្នាដើម្បីសហគមន៍ប្រើប្រាស់ភាសាបារាំង

Volontaires unis pour la francophonie

17.11.2026
10h

សន្និសីទ | CONFÉRENCE

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE
(ESPACE CONFÉRENCES)



© Régis Binard



© CIRAD

ភាសាបារាំង និងការចល័ត
Langue française et mobilités

កិច្ចពិភាក្សាតុមូលនេះ នឹងគូសបញ្ជាក់ពីការងារស្ម័គ្រចិត្តអន្តរជាតិ ក្នុងនាមជាចលករជំរុញការលើកកម្ពស់ភាសាបារាំង កិច្ចសហប្រតិបត្តិការអន្តរវប្បធម៌ និងការចូលរួមរបស់យុវជននៃសហគមន៍ប្រើប្រាស់ភាសាបារាំង។ តាមរយៈការចែករំលែកបទពិសោធន៍ផ្ទាល់របស់អ្នកស្ម័គ្រចិត្ត កម្មវិធីនេះនឹងបង្ហាញពីគំនិតផ្តួចផ្តើមនានា និងបទពិសោធន៍ការងារទាំងឡាយ ដែលរួមចំណែកដល់ការផ្សព្វផ្សាយភាពលេចធ្លោនៃសហគមន៍ប្រើប្រាស់ភាសាបារាំង ព្រមទាំងការផ្លាស់ប្តូររវាងបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង។

Cette table ronde mettra en lumière le volontariat international comme levier de promotion du français, de coopération interculturelle et d'engagement des jeunes francophones. À travers des témoignages de volontaires, elle présentera les initiatives et parcours contribuant au rayonnement de la Francophonie et aux échanges entre les pays francophones.

រៀបចំ និងដឹកនាំដោយ | Organisé par

France Volontaires Cambodge

ការដាំដុះដំណាំស្រូវប្រកបដោយចីរភាព

Les Rizicultures durables

17.11.2026
16h

វេទិកាតុមូល | TABLE RONDE

ភូមិហ្វ្រង់កូហ្វូនី(ផ្នែកសន្និសីទ)
VILLAGE DE LA FRANCOPHONIE (ESPACE CONFÉRENCES)



©IRD/Yann Bigant

ការដាំដុះដំណាំស្រូវ ដែលជាមូលដ្ឋានដ៏សំខាន់មិនអាចខ្វះបានសម្រាប់សន្តិសុខស្បៀង និងសេដ្ឋកិច្ចនៅកម្ពុជា កំពុងវិវត្តទៅរកគំរូផលិតកម្មប្រកបដោយចីរភាពជាងមុន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ កិច្ចពិភាក្សាតុមូលនេះ នឹងលើកបង្ហាញពីសារៈសំខាន់នៃការថែរក្សាសុខភាពដី ការអភិរក្សជីវចម្រុះ និងព្រមទាំងភាពចម្រុះនៃពូជស្រូវប្រពៃណីផ្សេងៗ រួមមានស្រូវផ្កាម្លិះជាដើម។ កិច្ចពិភាក្សានេះ ក៏នឹងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរពីវិធីសាស្ត្របង្កើនទិន្នផលខ្លាំងក្លាកាលពីសម័យមុន ទៅរកការអនុវត្តកសិកម្មបែបអេកូឡូស៊ី ដែលអាចធានាសន្តិសុខស្បៀង ព្រមទាំងការពារប្រព័ន្ធអេកូឡូស៊ី។

La riziculture, pilier indispensable de l'alimentation et de l'économie au Cambodge, évolue vers des modèles plus durables face aux contraintes environnementales et climatiques. Cette table ronde met en valeur l'importance de préserver la santé des sols, la richesse de la biodiversité et la diversité génétique des variétés de riz traditionnelles, comme le riz Jasmin. Elle invite à dépasser les méthodes intensives d'autrefois pour adopter des pratiques agroécologiques capables d'assurer la sécurité alimentaire tout en protégeant les écosystèmes.

វិទ្យាសាស្ត្រ និងការអភិវឌ្ឍប្រកបដោយចីរភាព
Sciences et développement durable

រៀបចំ និងដឹកនាំដោយ | Organisé par

Institut de Recherche pour le Développement (IRD)
Centre de coopération internationale en recherche agronomique pour le développement (CIRAD)

ការប្រគំតន្ត្រី "Duo I Nu"

Duo I Nu

17.11.2026
17h

ប្រគំតន្ត្រី | CONCERT

ភូមិហ្វ្រង់កូហ្វូនី (ផ្នែកសម្តែងសិល្បៈវប្បធម៌)
VILLAGE DE LA FRANCOPHONIE
(SCÈNE PERFORMANCES
CULTURELLES)



វប្បធម៌ និង
ការច្នៃប្រឌិត
Culture
et Création

កោះនូវែលកាលេដូនី សូមអញ្ជើញលោកអ្នកមកទស្សនា និងរីករាយជាមួយការប្រគំតន្ត្រីអមដោយហ្គីតា របស់ Duo I Nu ដែលមានសមាជិកពីររូប គឺ Hnawejë ជាអ្នកលេងហ្គីតា និងជាអ្នកចម្រៀងមកពីកោះ Lifou និង Marianne ជាអ្នកចម្រៀង អ្នកលេងយូខូលេលេ (ukulele) និងឧបករណ៍បង្កើតសូរស័ព្ទភ្លេង (mélodiciste) មកពីតំបន់ Normandie ប្រទេសបារាំង។ ស្នាដៃតន្ត្រីរបស់ពួកគេ រួមបញ្ចូលគ្នានូវឥទ្ធិពលវប្បធម៌ជនជាតិដើមកាណាក់ បារាំង និងតន្ត្រីសហសម័យ ដែលឆ្លុះបញ្ចាំងពីភាពសម្បូរបែបនៃវប្បធម៌ក្នុងសហគមន៍ប្រើប្រាស់ភាសាបារាំង។

La Nouvelle-Calédonie vous invite à un concert voix-guitare porté par le Duo I Nu, formé de Hnawejë, guitariste et chanteur originaire de Lifou, et de Marianne, chanteuse, ukuléliste et mélodiciste venue de Normandie. Leur univers mêle influences kanak, françaises et contemporaines, et illustre toute la richesse culturelle de l'espace francophone.

រៀបចំ និងនាំមកជូនដោយ | Présenté par

Gouvernement de la Nouvelle-Calédonie
Centre de Rencontres et d'Echanges Internationaux du Pacifique (CREIPAC)

ការចាក់បញ្ចាំងមុនគេនូវភាពយន្តខ្លី ចតុ "សំឡេងថ្មីៗនៃភាពយន្តកម្ពុជា"

Avant-première des courts métrages CHAKTO “Les nouvelles voix du cinéma cambodgien”

17.11.2026
18h30

ភាពយន្ត | CINÉMA

វិទ្យាស្ថានបារាំង (រោងភាពយន្ត)
INSTITUT FRANÇAIS (CINÉMA)





ពួកគេបានសរសេរសាច់រឿង ថត និងកាត់តភាពយន្តរួចរាល់ហើយ។ ឥឡូវនេះ ដល់ពេលនាំស្នាដៃរបស់ពួកគេមកបង្ហាញលើអេក្រង់ហើយ! បន្ទាប់ពីចំណាយពេលជាងមួយឆ្នាំធ្វើការយ៉ាងជិតស្និទ្ធជាមួយ Anti-Archive ផលិតករភាពយន្តវ័យក្មេងនៃកម្មវិធីចតុភាពយន្ត (CHAKTO Cinéma) នឹងបង្ហាញជូនទស្សនិកជននូវស្នាដៃភាពយន្តខ្លីរបស់ពួកគេ។ ទស្សនៈថ្មីៗ ពិភពសាច់រឿងប្លែកៗ ដែលគួរឱ្យស្វែងយល់ និងឱកាសជួបជាមួយអ្នកបង្កើតភាពយន្តជំនាន់ថ្មីរបស់កម្ពុជា គឺជាព្រឹត្តិការណ៍ដែលមិនគួររំលងឡើយ មុនពេលភាពយន្តទាំងនេះចេញដំណើរទៅចូលរួមមហោស្រពភាពយន្តអន្តរជាតិនានា។

Ils ont écrit, tourné, monté. Et maintenant, place à l’écran ! Après plus d’un an de travail aux côtés d’Anti-Archive, les jeunes cinéastes du programme CHAKTO Cinéma vous dévoilent leurs courts métrages. Des regards neufs, des univers à découvrir, et un rendez-vous avec la nouvelle génération du cinéma cambodgien à ne pas manquer, avant que ces films ne prennent la route des festivals internationaux.

ជាមួយ | Avec

Seng Savunthara & Phorn Sophanith
et le collectif Anti-Archive

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création





CHAKTO

រាត្រីបិទកម្មវិធីជាមួយ ឌីជេ StillCa$hRules

Soirée de clôture avec DJ StillCa$hRules

17.11.2026
20h

ឈុតឌីជេ | DJ SET

វិទ្យាស្ថានបារាំងនៅកម្ពុជា (IFC)
INSTITUT FRANÇAIS



វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

ដើម្បីបិទបញ្ចប់ព្រឹត្តិការណ៍ដ៏សំខាន់នេះរបស់សហគមន៍ប្រើប្រាស់ភាសាបារាំងជាមួយនឹងសូរសៀងតន្ត្រី វិទ្យាស្ថានបារាំងសូមស្វាគមន៍ឌីជេ StillCa$hRules ដែលជាបុគ្គលលេចធ្លោមួយរូបក្នុងវិស័យវប្បធម៌ និងតន្ត្រីកម្ពុជា។ ឌីជេ StillCa$hRules សូមអញ្ជើញអ្នកទាំងអស់គ្នាមកបន្តអបអរសាទរស្មារតីនៃកិច្ចប្រជុំកំពូល តាមរយៈការរាំកម្សាន្តលាយតន្ត្រី ដោយឌីជេ (DJ set) ដ៏សម្បូរបែប និងមានចម្រុះរសជាតិ ដែលឆ្លុះបញ្ចាំងពីសហគមន៍ប្រើប្រាស់ភាសាបារាំងដែលបើកចំហ មានភាពច្នៃប្រឌិត និងសម្បូរបែប។ សូមមកជួបជុំគ្នានៅវិទ្យាស្ថានបារាំង ដើម្បីរួមគ្នាអបអរសាទរសហគមន៍ប្រើប្រាស់ភាសាបារាំងតាមរយៈតន្ត្រី!

Pour clôturer en musique ce grand rendez-vous de la Francophonie, l'Institut français accueille DJ StillCa$hRules, figure incontournable de la scène culturelle et musicale cambodgienne. Il nous invite à prolonger l'esprit du Sommet sur la piste de danse, avec un DJ set généreux et éclectique, à l'image d'une Francophonie ouverte, créative et plurielle. Rendez-vous à l'Institut français pour célébrer ensemble la Francophonie en musique !

ជាមួយ | Avec

DJ StillCa$hRules aka Sok Visal, artiste, réalisateur, producteur et DJ

កម្មវិធីទស្សនាពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៧ ខែវិច្ឆិកា
À voir du 13 au 17 novembre

ទឹកស្អាតសម្រាប់ទាំងអស់គ្នា
Fontaine à eau en libre accès

ភូមិហ្វ្រង់កូហ្វូនី
VILLAGE DE LA FRANCOPHONIE

វិទ្យាសាស្ត្រ និងការអភិវឌ្ឍ ប្រកបដោយចីរភាព
Sciences et développement durable

អស់រយៈពេល ៣០ឆ្នាំមកហើយ ដែលប្រទេសបារាំងនិងប្រទេសកម្ពុជា បានធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធដើម្បីលើកកម្ពស់លទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគនៅរាជធានីភ្នំពេញ។ ក្នុងឱកាសនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ និងដើម្បីបង្ហាញជានិមិត្តរូបនូវភាពជោគជ័យនៃកិច្ចសហប្រតិបត្តិការដ៏ផ្លែផ្កានេះ ដែលបានជួយឱ្យប្រជាពលរដ្ឋនៅក្នុងរាជធានីភ្នំពេញបានទទួលសេវាផ្គត់ផ្គង់ទឹកស្អាតគ្រប់ៗគ្នា ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) បានរៀបចំពិធីសម្ពោធកន្លែងផ្តល់ទឹកស្អាតមួយសម្រាប់បរិភោគ។ កន្លែងផ្តល់ទឹកស្អាតនេះនឹងអនុញ្ញាតឱ្យអ្នកចូលរួមទាំងអស់ អាចទទួលទានទឹកបានដោយសុវត្ថិភាពនៅភូមិហ្វ្រង់កូហ្វូនី ។ បច្ចុប្បន្ន នៅរាជធានីភ្នំពេញ មនុស្សជាង ១,៣ លាននាក់មានលទ្ធភាពទទួលបានទឹកស្អាតសម្រាប់បរិភោគ តាមរយៈគម្រោងបាក់ខែង ដែលទទួលបានហិរញ្ញប្បទានរួមគ្នាពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ធនាគារវិនិយោគអឺរ៉ុប (EIB) សហភាពអឺរ៉ុប (EU) និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA)។

Depuis 30 ans, la France et le Cambodge travaillent main dans la main pour améliorer l'accès à l'eau potable à Phnom Penh. A l'occasion XX ème Sommet de la Francophonie et afin de symboliser ce partenariat fructueux qui a permis aux habitants de la capitale du Cambodge d'avoir un accès universel au service d'eau potable, l'Agence française de développement (AFD) et la régie des eaux de Phnom Penh (PPWSA) inaugurent une fontaine d'eau potable. Cette fontaine permettra à chacune et chacun d'y boire de l'eau en toute sécurité au Village de la Francophonie. Aujourd'hui, à Phnom Penh, ce sont plus d'1,3 million de personnes qui ont accès à l'eau potable grâce au projet Bakheng, co-financé par l'AFD, la Banque européenne d'investissement (BEI), l'Union européenne (UE) et la PPWSA.



សារ/រូបភាព ៖ សិល្បៈរចនាក្រាហ្វិកដើម្បីផលប្រយោជន៍សាធារណៈ

Exposition Messages / Images Graphisme d'intérêt général





វិទ្យាស្ថានបារាំងនៅកម្ពុជា
INSTITUT FRANÇAIS DU CAMBODGE

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

ភាសាបារាំង និងការចល័ត
Langue française et mobilités

វិទ្យាស្ថានបារាំងនៅកម្ពុជា ទទួលរៀបចំពិព័រណ៍ "សារ/រូបភាព ៖ សិល្បៈរចនាក្រាហ្វិកដើម្បីផលប្រយោជន៍សាធារណៈ" ដែលកើតចេញពីភាពជាដៃគូរវាងមជ្ឈមណ្ឌលអន្តរជាតិនៃភាសាបារាំង និងមជ្ឈមណ្ឌលជាតិសិល្បៈទស្សនីយរបស់បារាំង (CNAP)។ ក្រៅពីរូបភាពដែលជាស្នាដៃរបស់អ្នករចនា និងអ្នករចនាក្រាហ្វិកបារាំងក្នុងការតាំងពិព័រណ៍ដើម យើងក៏នឹងមានដាក់តាំងបង្ហាញផ្ទាំងរូបភាពចំនួនប្រាំពីរផ្ទាំងទៀត ដែលបង្កើតឡើងដោយអ្នករចនាក្រាហ្វិកកម្ពុជា ក្នុងលក្ខណៈជាស្នាដៃឆ្លុះបញ្ចាំងគ្នាជាមួយស្នាដៃដើម។ ផ្ទាំងរូបភាពទាំងនេះ ត្រូវបានបង្កើតឡើងក្រោមប្រធានបទដូចគ្នា ដោយលើកយកធាតុផ្សំនៃវប្បធម៌ និងសិល្បៈរចនាតួអក្សរខ្មែរ មកប្រើប្រាស់ដើម្បីបង្ហាញទស្សនៈដ៏ពិសេសរបស់កម្ពុជាចំពោះបញ្ហាប្រឈមនានាក្នុងសម័យទំនើប។

L'exposition *Messages/Images : graphisme d'intérêt général* est portée par la Cité internationale de la langue française et le Centre national des arts plastiques (CNAP). En plus des affiches des designers et graphistes français de l'exposition originelle, sept affiches "en miroir" réalisées par des graphistes cambodgiens seront exposées. Réalisées sur les mêmes thématiques, elles encouragent les références culturelles et l'art de l'alphabet khmer pour offrir un regard cambodgien unique sur les enjeux contemporains.

មហោស្រពរូបថតភ្នំពេញ - ការបោះពុម្ពពិសេសហ្វ្រង់កូហ្វូនី

Festival Photo Phnom Penh – Édition spéciale Francophonie



តាមទីតាំងដៃគូសហការក្នុងភ្នំពេញ
LIEUX MULTIPLES DANS TOUT PHNOM PENH

វប្បធម៌ និង ការច្នៃប្រឌិត
Culture et Création

ឆ្នាំនេះ មហោស្រពរូបថតភ្នំពេញ នាំមកជូននូវកម្មវិធីពិសេសស្តីពីហ្វ្រង់កូហ្វូនី! សូមអញ្ជើញមកទស្សនា និងស្វែងយល់ពីស្នាដៃរបស់សិល្បករថតរូបដែលប្រើប្រាស់ភាសាបារាំងមកពីជុំវិញពិភពលោក ព្រមទាំងឆ្លៀតឱកាសដើរទស្សនារាជធានីភ្នំពេញផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័ររបស់មហោស្រព។

Le Festival Photo Phnom Penh propose cette année une édition spéciale francophonie ! Découvrez les expositions de plus de 28 photographes francophones du monde entier répartis dans 11 lieux emblématiques de la ville. Plus d'informations sur https://photophnompenh.com/

ព្រឹត្តិការណ៍ផ្សេងៗ
Événements associés

សន្និសីទ | CONFÉRENCE

សារមន្ទីរ ព្រះស្រីឡៀសានវរ៉ុន (ស.ស.រ)
MUSÉE SOSORO

La Francophonie en Asie-Pacifique : Héritages, éducation et vécu

12.11.2026
18h30

ជាមួយ | Avec

Pierre Journoud, Magali Bigaud & Lim Bunhok

រៀបចំ និងដឹកនាំដោយ | Organisé par

Musée SOSORO, avec l'Institut de Recherche sur l'Asie du Sud-Est Contemporaine (IRASEC) et l'Université Royale de Droit et des Sciences Économiques (URDSE)

ភាសាបារាំង និងការចល័ត
Langue française et mobilités

L'écho de Phnom Penh (1966 - 2026), du discours aux héritages d'une vision du monde

De Gaulle in Phnom Penh, 1966: Promoting a New World Order

13.11.2026
18h30

ជាមួយ | Avec

Pierre Journoud, Professeur d'histoire contemporaine à l'Université Paul-Valéry Montpellier 3

រៀបចំ និងដឹកនាំដោយ | Organisé par

Musée SOSORO, avec l'Institut de Recherche sur l'Asie du Sud-Est Contemporaine (IRASEC) et l'Université Royale de Droit et des Sciences Économiques (URDSE)

ភាសាបារាំង និងការចល័ត
Langue française et mobilités

ការសម្របសម្រួលទូទៅ
Coordination générale

AMBASSADE DE FRANCE AU CAMBODGE
Liberté
Égalité
Fraternité

INSTITUT FRANÇAIS
Cambodge

ក្រុមការងារបារាំង
Équipe France

INSTITUT FRANÇAIS

AFD GROUPE

EXPERTISE FRANCE
GROUPE AFD

IRD
Déployer la recherche
Partager la science
Transformer l'avenir

cirad

Institut Pasteur du Cambodge
PASTEUR NETWORK

IRASEC

France Volontaires
Cambodge

CAMPUS FRANCE
CAMBODGE

aefe
Agence pour l'enseignement français à l'étranger

LYCÉE FRANÇAIS
RENÉ DESCARTES
PHNOM PENH • 1951

AllianceFrançaise
Siem Reap

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

inpi
FRANCE

Alliance francophone de la propriété intellectuelle

École française d'Extrême-Orient
EFEO

ដៃគូសហការ
Partenaires

SOSORO MUSEUM

Spedidam

ASK MONA

CREIPAC
Centre de Rencontres et d'Échanges Internationaux du Pacifique

Cité internationale de la langue française
Château de Villers-Cotterêts

BRED BANK CAMBODIA
The smarter way to bank.

ដៃគូសហការផ្នែកប្រព័ន្ធផ្សព្វផ្សាយ
Partenaires média

TV5 MONDE

BÁNH MÌ MEDIA